ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គជអប
NCDD

លេខាធិការដ្ឋានគណៈកម្មាធិការជាតិ

សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍

# ស្តីពី វឌ្ឍនភាពការងារសុវត្ថិភាព បរិស្ថាន និងសង្គម ឆ្នាំ២០១៩



រៀបចំដោយ ៖ អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី

ខែធ្នូ ឆ្នាំ២០១៩

# មាតិកា


១. សេចក្តីផ្តើម…………………………………………………………………………… ១
២. សកម្មភាព និងលទ្ធផលសម្រេចបាន…………………………………………………… ១
២.១.បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៩ តម្រូវការសិក្សាសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច……………………… ៣
២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់……………………………………………… ៣
២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក………………………………………………… ៤
២.១.៣.បញ្ជីគម្រោងមូលនិធិរាជធានី ខេត្ត……………………………………………… ៥
២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង ឆ្នាំ២០១៩ ៦
២.២.១.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់…………… ៦
២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុក…………… ៦
២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្ត………… ៧
២.៣.ការត្រួតពិនិត្យឯកសារ និងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃគម្រោងឆ្នាំ២០១៨… ៧
២.៤.ការពង្រឹងសមត្ថភាព…………………………………………………………… ៨
២.៥.សកម្មភាពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ……………………………………… ៨
២.៦.ការគាំទ្រ និងកិច្ចសហការ……………………………………………………… ១០
៣. បញ្ហាប្រឈមនានា………………………………………………………………… ១០
៤. ការសន្និដ្ឋាន……………………………………………………………………… ១១
៥. អនុសាសន៍ ……………………………………………………………………… ១២
៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០២០…………………………………………… ១៣
៧. ឧបសម្ព័ន្ធ៖
៧.១.តារាងតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពគម្រោងឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ឆ្នាំ២០១៩ និងការពិនិត្យនិងផ្តល់យោបល់បច្ចេកទេស
៧.២. បញ្ជីឈ្មោះមន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
៧.៣. រូបថតសកម្មភាពរបស់ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច

## ១. សេចក្តីផ្តើម

គណៈកម្មាធិការជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលជាកំណែទម្រង់ផ្នែកអភិបាលកិច្ចដ៏មានសារៈសំខាន់របស់រាជរដ្ឋាភិបាល ហើយបានអនុវត្តចាប់តាំងពីឆ្នាំ២០០១មកម្ល៉េះ ព្រមទាំងបានបង្កើតនូវសមិទ្ធផលជាច្រើនពាក់ព័ន្ធទៅនឹងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ តាមរយៈកំណែទម្រង់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានបំពេញតួនាទី និងការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការអភិវឌ្ឍមូលដ្ឋាន ដែលប្រការនេះបានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ការលើកស្ទួយជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយទទួលបាននូវគម្រោងអភិវឌ្ឍមូលដ្ឋានជាច្រើនពីមូលនិធិរបស់រាជរដ្ឋាភិបាល និងពីដៃគូអភិវឌ្ឍន៍ មានដូចជា គម្រោងហេដ្ឋរចនាសម្ព័ន្ធរូបវន្ត និងគម្រោងសេវាកម្ម សម្រាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

គោលការណ៍ណែនាំស្តីពី ″សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច គឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ក្នុងគោលបំណងពង្រឹងការចូលរួម ការទទួលខុសត្រូវ តម្លាភាព និងប្រសិទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើកិច្ចការពារបរិស្ថាន និងសង្គម សមស្របតាមកម្រិតបទដ្ឋានជាតិ និងអន្តរជាតិនៅក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ។ គុណតម្លៃនៃកិច្ចការពារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិច មានសារៈសំខាន់ចំពោះសហគមន៍មូលដ្ឋានឱ្យទទួលបាននូវផលប្រយោជន៍ពីគម្រោង ការពារបាននូវធនធានធម្មជាតិនិងបរិស្ថាន និងមានសុវត្ថិភាពសង្គម។ ចំពោះអ្នកអនុវត្តគម្រោងវិញ គឺទទួលបាននូវការការពារទំនាស់នានាជាមួយសហគមន៍ និងបញ្ចៀសបាននូវការពន្យាពេលអនុវត្តគម្រោង និងបង្កើនតម្លៃគម្រោង។

កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាយន្តការមួយត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ យន្តការមួយនេះ ត្រូវបានប្រើប្រាស់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ដែលតម្រូវឱ្យអ្នកអនុវត្តគម្រោងត្រូវតែមានការប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់ជាមុនចំពោះហានិភ័យលើបរិស្ថាន និងសង្គម ដែលនឹងអាចកើតមានឡើងដោយសារការអនុវត្តគម្រោង។ ការប្រុងប្រយ័ត្នជាមុននេះ គឺអាចបញ្ចៀសបាន ឬកាត់បន្ថយឱ្យនៅកម្រិតទាបបំផុត ឬក៏សម្រាលបន្ទុកនៃផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន និងសង្គម ចំពោះភាគីទីបី ឬពុំអើពើចំពោះក្រុមជនងាយរងគ្រោះដែលទទួលរងឥទ្ធិពលពីការអនុវត្តគម្រោងនៅ។

## ២. សកម្មភាព និងលទ្ធផលសម្រេចបាន

ក្នុងឆ្នាំ២០១៩ ទីប្រឹក្សា និងមន្ត្រីផ្នែកសុវត្ថិភាពបរិស្ថាននិងសង្គម បានអនុវត្តន៍តាមផែនការសកម្មភាព និងថវិកាដែលបានលើកឡើងនៅដើមឆ្នាំ ហើយបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម ៖

- ធ្វើការទំនាក់ទំនងជាមួយមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយបានចងក្រងជាបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត សម្រាប់ផ្ទៀងផ្ទាត់ក្នុងការពិនិត្យ និងផ្តល់យោបល់បច្ចេកទេសផ្នែកសុវត្ថិភាពបរិស្ថាន និងជនជាតិដើមភាគតិចមុនដេញថ្លៃគម្រោង។

- ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវអនុវត្តគម្រោងនៅមូលដ្ឋាន តាមរយៈវគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញដោយសហការជាមួយគម្រោងនានាចំណុះឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប.។
- ពង្រឹងសមត្ថភាពមន្ត្រីនិងទីប្រឹក្សារបស់គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាបខ្នាតតូច (TSDD) តាមរយៈវគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញផ្នែកសុវត្ថិភាពបរិស្ថាន និងសង្គម។
- ចុះតាមដានការអនុវត្តសុវត្ថិភាពដីធ្លីរបស់គម្រោងក្រោយដេញថ្លៃរួច ហើយបានអនុវត្តរួចរាល់១០០% និងការពង្រឹងសមត្ថភាពដល់មន្ត្រីដែលអនុវត្តគម្រោងតាមរយៈការប្រជុំឆ្លុះបញ្ចាំងអំពីបេកគំហើញត្រលប់វិញ។
- ចូលរួមចុះវាយតម្លៃគម្រោងជាមួយមន្ត្រីនិងទីប្រឹក្សាគម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងអនុវត្តសកម្មភាពជាអាទិភាព(SRL)នៅខេត្តសៀមរាប និងខេត្តកំពង់ធំ។
- រៀបចំកសិករក្រុមសន្សំ ក្រុមសហគមន៍ប្រើប្រាស់ទឹក និងចុះវិភាគប្រមូលទិន្នន័យផលប៉ះពាល់ ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ ដើម្បី ឈានទៅរកការរៀបចំចេញនូវផែនការយុទ្ធសាស្ត្រថ្នាក់ ស្រុកជាមួយទីប្រឹក្សានិងមន្ត្រីនៃគម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងអនុវត្តសកម្មភាពជាអាទិភាព(SRL)ក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំ។
- ចូលរួមកែសម្រួលសេចក្ដីណែនាំស្ដីពីវិធានការបន្ធូរបន្ថយហានិភ័យដើម្បីប្រើប្រាស់គោលនយោបាយសុវត្ថិភាពបរិស្ថាននិងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងដាក់ឆ្លងថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។
- ចូលរួមវាយតម្លៃគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ(PBCR Grant) របស់កម្មវិធី(ASPIRE) នៃលេខាធិការដ្ឋាន គ.ជ.អ.ប ជាគម្រោងអនុវត្តនៅក្នុងឆ្នាំ២០១៧ មានដូចជា ផ្លូវក្រាលក្រួសក្រហម ស្ដារស្រះទឹក និងគម្រោងសេវាកម្មមួយចំនួននៅក្នុងស្រុកបាទី និងស្រុកបុរីជលសារ ខេត្តតាកែវ ដើម្បីទទួលមូលនិធិបន្ថែមលើមូលនិធិអនុវត្តគម្រោងប្រចាំឆ្នាំ។
- បានរៀបចំឯកសារទាក់ទងទៅនឹងកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គមនៃគម្រោងមូលនិធិឃុំ សង្កាត់ដែលជាបទពិសោធន៍នៃការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងដាក់បញ្ជូនទៅលោក Julien សម្រាប់ជាឯកសារយោងផ្ញើទៅមូលនិធិអាកាសធាតុបៃតង(Green Climate Fund)។
- បានចូលរួមធ្វើបទបង្ហាញក្នុងកម្មវិធីស្ដីពីវិធានការបន្ធូរបន្ថយហានិភ័យដើម្បីប្រើប្រាស់គោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅសាលប្រជុំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដល់មន្ត្រី និងទីប្រឹក្សារបស់លេខាធិការដ្ឋាននៅថ្នាក់ជាតិ។
- បានចូលរួមរៀបចំ និងផ្សព្វផ្សាយគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិជាមួយថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប.។
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងជាមួយមន្ត្រីនៃទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ផ្សារភ្ជាប់វគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញ ការពិភាក្សាផ្លាស់ប្ដូរយោបល់រកដំណោះស្រាយលើការប្រឈមនានាក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង។

- ចូលរួមសម្របសម្រួលផ្នែកសុវត្ថិភាពបរិស្ថាន និងសង្គមរបស់គម្រោងបែងចែកដី និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន២ (LASERD II) នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំងជាមួយមន្ត្រី និងទីប្រឹក្សាគម្រោងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងជាមួយទីប្រឹក្សានិងមន្ត្រីរបស់ធនាគារពិភពលោក(The World Bank) លើការត្រួតពិនិត្យគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលបានអនុវត្តរួចរាល់ក្នុងរយៈពេលបីឆ្នាំកន្លងទៅ។
- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើសុវត្ថិភាពបរិស្ថាន និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ឆ្នាំ២០១៨ ដែលនៅសេសសល់ និងគម្រោងឆ្នាំ២០១៩ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានផ្ញើមកមុនដេញថ្លៃគម្រោង។

## ២.១. ការពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៩ ដែលត្រូវការសិក្សាសុវត្ថិភាព

### ២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់

គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៩មានចំនួនសរុប**១៦៣៩**គម្រោងនៅក្នុង**១៥៣៧**ឃុំ សង្កាត់ ។ ក្នុងនោះតម្រូវការសិក្សាផលប៉ះពាល់បរិស្ថានសរុបចំនួន**៦៧៨**គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន**២៣៦**គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន៨៤គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប**៦៧៦**គម្រោង និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចមានចំនួនសរុប៨៤គម្រោង។ គម្រោងរាជធានីភ្នំពេញ មិនមាននៅក្នុងបញ្ជីទេ។ រូបភាពខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៤ ។

រូបភាពទី១៖ ក្រាហ្វិចចំនួនគម្រោង និងតម្រូវការសិក្សាសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច




នៅក្នុងគម្រោងសរុបចំនួន**១៦៣៩**នេះ មានផ្លូវដី ផ្លូវបេតុងអាមេ ផ្លូវក្រាលក្រួសក្រហមចំនួន**១៣២៨**ខ្សែ ស្ពានឈើ និងស្ពានឈើក្បាលបេតុងចំនួន**២១**កន្លែង ប្រព័ន្ធធារាសាស្ត្រមានប្រឡាយនិងទំនប់ចំនួន**១៨១**កន្លែង អណ្តូងស្នប់និងស្រះជីកចំនួន១៨កន្លែង សាលារៀនចំនួន**១២**កន្លែង និងផ្សេងៗដែលមានដូចជាប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹកភ្លៀង សំណង់ទីទួលសុវត្ថិភាពចំនួន**៥៦**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្តន៍។

រូបភាពទី២៖ ប្រភេទគម្រោងមូលនិធិឃុំ សង្កាត់




<u>**កំណត់សម្គាល់លើចំនួនគម្រោងដែលមានត្រូវការសិក្សាដីធ្លីបានថយចុះ**</u>

ការអភិវឌ្ឍនៅក្នុងសហគមន៍មូលដ្ឋាន ក្នុងអំឡុងពេលប្រាំឆ្នាំនេះ ដោយគិតចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ឃើញថា មានការថយចុះនៃចំនួនគម្រោងតម្រូវការសិក្សាសុវត្ថិភាពដីធ្លី ដោយសារនៅឃុំ សង្កាត់ភាគច្រើនបានបង្កើនចំនួនគម្រោងផ្លូវបេតុងអាមេរ៍ច្រើនជាងផ្លូវដី សម្រាប់បម្រើតាមសមណ្ឌមពរ និងតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋានដែលបានលើកឡើងមកក្រុមប្រឹក្សាឃុំ សង្កាត់។ រូបភាពខាងក្រោមបង្ហាញអំពីចំនួនគម្រោងសិក្សាដីធ្លីបានថយចុះ។

រូបភាពទី៣៖ វិភាគចំនួនគម្រោងតម្រូវការសិក្សាសុវត្ថិភាពដីធ្លីក្នុងអំឡុងឆ្នាំ២០១៥ ដល់២០១៩




## ២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក

គម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៩ មានចំនួនសរុប២០៧គម្រោងនៃ៨៧ក្រុង ស្រុក ខណ្ឌ របស់ខេត្តចំនួន១១។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន៨៦គម្រោង តម្រូវការសិក្សាដីធ្លី១២គម្រោង និងតម្រូវការសិក្សាជនជាតិដើមភាគតិចមាន១១គម្រោង។ ចំនួនគម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុប៨៦គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើង ។

រូបភាពទី៤៖ ចំនួនក្រុង ស្រុក ខណ្ឌ និងតម្រូវការសិក្សាសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច




នៅក្នុងគម្រោងសរុបចំនួន២០៧នេះ មានផ្លូវក្រួសក្រហម និងផ្លូវបេតុងអាមេរ៉ចំនួន២០៧ខ្សែ ស្ពានចំនួន៤កន្លែង ប្រព័ន្ធធារាសាស្ត្រមានប្រឡាយ និងទំនប់ចំនួន១៤កន្លែង អណ្តូងស្នប់និងស្រះចំនួន២កន្លែង ជួសជុលអគាររដ្ឋបាលសាលាស្រុកចំនួន១៤កន្លែង និងផ្សេងៗដែលមានជាប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹកភ្លៀង កែលម្អសួនច្បារ ជួសជុលរបងអាគារ ចាក់សាបទីធ្លាសាធារណៈ គ្រប់គ្រងសំណល់ តបណ្តាញបង្គោលអគ្គិសនីសាធារណៈចំនួន៤០កន្លែង។ រូបភាពខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្ត។

រូបភាពទី៥៖ ប្រភេទគម្រោងក្រុង ស្រុក ខណ្ឌ




## ២.១.៣.បញ្ជីគម្រោងមូលនិធិរាជធានី ខេត្ត

គម្រោងមូលនិធិរាជធានី ខេត្ត មានខេត្តចំនួន៧ បានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៩ មានចំនួនសរុប ៥៥គម្រោង ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន១៥គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន៩គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមានចំនួន១៩គម្រោង។ គម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប១៥គម្រោងក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចសរុបមានចំនួន១៩គម្រោង។ រូបភាពខាងក្រោមបង្ហាញពីចំនួនគម្រោងខេត្ត ដែលបានស្នើឡើងរបស់ខេត្តចំនួន៧ គឺខេត្តកំពង់ស្ពឺ កំពត កោះកុង កែប កំពង់ចាម មណ្ឌលគិរី និងប៉ៃលិន។

រូបភាពទី៦៖ ចំនួនគម្រោងខេត្ត និងតម្រូវការសិក្សាសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច



នៅក្នុងគម្រោងសរុបចំនួន៥៥នេះ មានផ្លូវក្រាលគ្រួសក្រហម ផ្លូវបេតុងអាមេ និងផ្លូវចាក់កៅស៊ូ DBST ចំនួន១៥ខ្សែ ប្រព័ន្ធធារាសាស្ត្រ មានទំនប់ដីចំនួន១គម្រោង ជួសជុលអគាររដ្ឋបាលចំនួន១២កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូដោះទឹក ជួសជុលនិងសាងសង់បណ្ដាញបង្គោលភ្លើងបំភ្លឺផ្លូវ ថែលម្អសួនច្បារសាធារណៈចំនួន១៥កន្លែង។ រូបភាពខាងក្រោមបង្ហាញពីប្រភេទគម្រោងដែលបានអនុវត្តរួចរាល់។

រូបភាពទី៧៖ ប្រភេទគម្រោងមូលនិធិខេត្តដែលបានអនុវត្តរួចរាល់




## ២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង

### ២.២.១.ការពិនិត្យនិងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានចំនួនសរុប៥១៧គម្រោង ស្មើនឹង៧៦%នៃចំនួនសរុប៦៧៦គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន៥៦គម្រោង ស្មើនឹង៨០%នៃចំនួន៨៣គម្រោង ដែលស្ថិតក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិច។

នៅដើមឆ្នាំ បានពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើបរិស្ថានគម្រោងឃុំ សង្កាត់ដែលនៅសេសសល់ក្នុងឆ្នាំ២០១៨ មានចំនួន៥២គម្រោង និងលើវិធានការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន២២ គម្រោង។

រូបភាពទី៨៖ ចំនួនគម្រោងឃុំ សង្កាត់ និងភាគរយដែលបានពិនិត្យនិងផ្តល់យោបល់




### ២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុក ខណ្ឌ

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិក្រុង ស្រុក ខណ្ឌ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីងាយរងទទួលនូវផលប៉ះពាល់បរិស្ថានចំនួនសរុប៨៦គម្រោងស្មើនឹង៧១% នៃចំនួនសរុប១២១គម្រោង និងរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន៨គម្រោង នៃចំនួន១១គម្រោងស្មើនិង៧៣%។

រូបភាពទី៩៖ ចំនួនគម្រោងក្រុង ស្រុក ខណ្ឌ និងភាគរយដែលបានពិនិត្យ




## ២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្ត

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានចំនួន២៤គម្រោងស្មើនឹង៦៧%នៃចំនួន៣៦គម្រោង ។ មិនមានពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចទេ។

រូបភាពទី១០៖ ចំនួនគម្រោងខេត្ត និងភាគរយដែលបានពិនិត្យ




## ២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃគម្រោង ឆ្នាំ២០១៨

បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៨នៅទីចាត់ការផែនការ និងវិនិយោគខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ ក្នុងខេត្តទាំងពីរនេះ មន្ត្រី និង ទីប្រឹក្សា បានត្រួតពិនិត្យគម្រោង ដីធ្លីសរុបចំនួន៣២គម្រោង ស្មើនឹង ៨៤% នៃគម្រោងមូលនិធិឃុំ សង្កាត់ ដែលតម្រូវការសិក្សាដីធ្លីសរុបចំនួន៤២គម្រោង។ ដំណើរការនៃការត្រួតពិនិត្យឯកសារ និងរបាយការណ៍ដីធ្លីនេះ រៀបចំឡើងនៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងនៅសាលាឃុំ សង្កាត់ ដោយបានផ្ទៀងផ្ទាត់របាយការណ៍ជាឯកសារច្បាប់ដើម និងបានចុះទៅតាមទីតាំងគម្រោងពិនិត្យគុណភាពគម្រោង និងជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង ដើម្បីសាកសួរយោបល់និងមតិពីពួកគាត់លើការអនុវត្តសុវត្ថិភាពដីធ្លីរបស់គម្រោង។ បន្ទាប់ពីបញ្ចប់រាល់ការពិនិត្យឯកសារ និងចុះត្រួតពិនិត្យនៅទីតាំងគម្រោងរួចមក ក្រុមសុវត្ថិភាព បានប្រជុំឆ្លុះបញ្ចាំងជាមួយនាយក នាយករង និងមន្ត្រីនៃទីចាត់ការផែនការ និងវិនិយោគខេត្ត រួមជាមួយមន្ត្រីពាក់ព័ន្ធ បង្ហាញអំពីលទ្ធផលដែលបានរកឃើញ ផ្តល់យោបល់លើចំណុចខ្វះខាត ដើម្បីជាមេរៀននិងបទពិសោធន៍សម្រាប់អនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីនៅឆ្នាំបន្តបន្ទាប់ ដោយត្រូវបញ្ចៀសបាន ឬកាត់បន្ថយនូវបញ្ហា និងហានិភ័យលើបរិស្ថាន ដីធ្លី និងវិធានការការពារសុវត្ថិភាពជនជាតិដើម

ភាគតិចឱ្យនៅកម្រិតទាបបំផុត។ តារាងខាងក្រោមបង្ហាញអំពីចំនួនឯកសារបាយការណ៍សិក្សាដីធ្លីរបស់គម្រោង ដែលក្រុមសុវត្ថិភាពបានត្រួតពិនិត្យ។

តារាងទី១៖ ចំនួនគម្រោងឆ្នាំ២០១៨ ដែលសិក្សាដីធ្លី និងភាគរយដែលបានចុះត្រួតពិនិត្យ

| ល.រ | ឈ្មោះខេត្ត | គម្រោងសរុប | គម្រោង សិក្សាដីធ្លី | គម្រោងត្រូវបានពិនិត្យ | ចំនួន% |
|---|---|---|---|---|---|
| ១ | កំពង់ឆ្នាំង | ៦២ | ១១ | ១១ | ១០០% |
| ២ | ស្វាយរៀង | ៨៦ | ៣១ | ២១ | ៦៧% |
| សរុប | | ១៤៨ | ៤២ | ៣២ | ៨៤% |

## ២.៤. ការពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ

- បានចូលរួមប្រជុំពិភាក្សាស្តីពីការរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីបរិស្ថាននិងសង្គម និង គោលនយោបាយស្តីពីសមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិដែលបានរៀបចំនៅសាលប្រជុំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។
- បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្នែកកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម និងបានចូលរួមក្នុង វគ្គបណ្តុះបណ្តាលស្តីពីការសិក្សាផែនទីភូមិសាស្ត្រលើតំបន់ងាយរងគ្រោះដោយធម្មជាតិដែលរៀបចំ ដោយធនាគារអភិវឌ្ឍអាស៊ី(ADB) ដើម្បីពង្រឹងសមត្ថភាពបន្ថែម។
- បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញផ្នែកកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម ក្នុង គម្រោងអភិវឌ្ឍន៍នៅជនបទរបស់ធនាគារអភិវឌ្ឍអាស៊ី(ADB)ដែលរៀបចំនៅក្នុងសណ្ឋាគារ ហ៊ីម៉ាវ៉ារីនៅក្នុងរាជធានីភ្នំពេញ ដើម្បីពង្រឹងសមត្ថភាពបន្ថែម។

## ២.៥. សកម្មភាពពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ

- បានចូលរួមសម្របសម្រួលជាគ្រូឧទ្ទេសផ្នែកបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីលទ្ធកម្ម និងកិច្ចការពារសុវត្ថិភាពសម្រាប់គម្រោងហេដ្ឋារចនា សម្ព័ន្ធឃុំ សង្កាត់ និងមន្ត្រីអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចក្នុងតំបន់ទន្លេសាប ជំហាន២។ សិក្ខាសាលាលើកទីមួយនេះ មានសិក្ខាកាមចូលរួមសរុបចំនួន៣៦៦នាក់ ដែលមកពីខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ។
- បានចូលរួមក្នុងកិច្ចប្រជុំការងារត្រួតពិនិត្យលើឯកសារគម្រោងអភិវឌ្ឍន៍ក្នុងដីសម្បទានសង្គមកិច្ចរបស់ គម្រោង (LASED II) នៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដោយបានចូលរួមផ្តល់យោបល់ផ្នែកសុវត្ថិ ភាពបរិស្ថាន និងសង្គមជាមួយមន្ត្រីនិងទីប្រឹក្សាគម្រោងមុនពេលដែលបេសកកម្មត្រួតពិនិត្យផ្នែកសុវត្ថិភាពបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោកចុះទៅខេត្តគោលដៅ។
- បានចូលរួមក្នុងកិច្ចប្រជុំជាមួយទីប្រឹក្សា និងមន្ត្រីរបស់ធនាគារពិភពលោក មន្ត្រីរបស់ក្រសួងសុខាភិបាល នៅសាលប្រជុំរបស់ធនាគារពិភពលោក ដោយបានពិភាក្សាអំពីសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងគ្រោងការគម្រោង ផ្តល់ចំណីអាហារនៅកម្ពុជារបស់ធនាគារពិភពលោកទៅខេត្តចំនួនប្រាំពីរនៅក្នុងតំបន់ខ្ពង់រាបនៅក្នុងប្រទេសកម្ពុជា ដែលបានផ្តោតលើតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ។

• បានចូលរួមសម្របសម្រួលជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាននិងសង្គមរបស់គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប ដំណាក់កាលទី២ ដែលគាំទ្រដោយធនាគារអភិវឌ្ឍអាស៊ី ដល់មន្ត្រីគាំទ្រគម្រោងនៅឃុំសង្កាត់ក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម ត្បូងឃ្មុំ និងព្រៃវែង សរុបចំនួន៣៦៦នាក់។ សិក្ខាសាលាលើកទីពីរនេះ ក្រុមសុវត្ថិភាព បានជួយសម្របសម្រួលដល់មន្ត្រីគាំទ្រគម្រោងឱ្យបានយល់កាន់តែច្បាស់អំពីកិច្ចការពារបរិស្ថាននិងសង្គមរបស់គម្រោង ការបំពេញទម្រង់ និងដំណាក់កាលនៃការអនុវត្តលើការវិភាគលើបរិស្ថាន សិក្សាដីធ្លី និងសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោង។

• បានចូលរួមក្នុងកិច្ចប្រជុំការងារជាមួយទីប្រឹក្សាការងារសុវត្ថិភាពរបស់ធនាគារអភិវឌ្ឍអាស៊ី(Asean Development Bank) ជាមួយទីប្រឹក្សាគម្រោងលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅជុំវិញបឹងទន្លេសាប(TSDD) ពិភាក្សាលើឯកសារសុវត្ថិភាពដីធ្លីរបស់គម្រោងអភិវឌ្ឍន៍ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញដល់មន្ត្រីនៅថ្នាក់ក្រោមជាតិមុននឹងចុះអនុវត្តគម្រោង។

• បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំស្តីពីការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងនៅថ្នាក់ក្រោមជាតិ និងវគ្គរំលឹកឡើងវិញផ្នែកនេះដល់មន្ត្រីទីចាត់ការផែនការ និងវិនិយោគខេត្ត។ កិច្ចប្រជុំនេះ រៀបចំឡើងនៅសាលប្រជុំនៃលេខាធិការដ្ឋាន គ.ជ.អ.ប មានរយៈពេលពីរថ្ងៃគឺថ្ងៃទី២០ និង២១ ខែមិថុនា ឆ្នាំ២០១៩ ដែលមានសិក្ខាចូលរួមមកពីខេត្តចំនួន២១ ជានាយក នាយករង ទីចាត់ការផែនការ និងវិនិយោគខេត្ត ជាប្រធាន អនុប្រធាន និងជាមន្ត្រីនៃការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ជាប្រធាន អនុប្រធាន និងជាមន្ត្រីការិយាល័យគាំទ្រមូលដ្ឋាន ជាអ្នកទទួលបន្ទុកគាំទ្រការអនុវត្តគម្រោងផ្ទាល់ សរុបចំនួន៦០នាក់ស្ត្រី៤នាក់ (មន្ត្រីនិងទីប្រឹក្សារបស់លេខាធិការដ្ឋាន គ.ជ.អ.ប ចំនួន៧នាក់ស្ត្រី១នាក់)។ លទ្ធផលនៃអង្គប្រជុំបានពិភាក្សាគ្នាស្វែងរកបញ្ហានិងដំណោះស្រាយ ក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពដើម្បីអនុវត្តក្នុងគម្រោងនៅថ្នាក់ក្រោមជាតិប្រកបដោយភាពរលូន និងមានតម្លាភាព។ សូមបញ្ជាក់ថា ខេត្តស្វាយរៀង ខេត្តកោះកុង និងខេត្តព្រះសីហនុ អវត្តមានក្នុងកិច្ចប្រជុំ។

• បានរៀបចំវគ្គរំលឹកឡើងវិញស្តីពីសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងនៅថ្នាក់ក្រោមជាតិនៅខេត្តឧត្តរមានជ័យ ដល់មន្ត្រីនៃទីចាត់ការផែនការ និងវិនិយោគខេត្ត មេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់ និងស្មៀនឃុំ សង្កាត់ ដែលជាមន្ត្រីអនុវត្តគម្រោង។ វគ្គរំលឹកឡើងវិញនេះ មានរយៈពេលពីរថ្ងៃ បានរៀបចំនៅសាលប្រជុំរបស់សាលាខេត្តឧត្តរមានជ័យ សិក្ខាកាមដែលចូលរួមមកពីទីចាត់ការផែនការ និងវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ចំនួន៦៨រូប ស្ត្រីចំនួន៧រូប (ក្នុងនេះថ្នាក់ជាតិចំនួន៥រូប ស្រី១រូប ដែលជាគ្រូឧទ្ទេស និងអ្នកសម្របសម្រួលវគ្គ)។ គោលបំណងនៃវគ្គរំលឹកឡើងវិញនេះ រៀបចំឡើងដើម្បី៖ ក)កែលម្អចំណុចខ្វះចន្លោះដែលរកឃើញក្នុងការត្រួតពិនិត្យឯកសារ ការអនុវត្តជាក់ស្តែងនៅទីតាំងគម្រោង និងបំពេញបន្ថែមចំណុចខ្វះចន្លោះមួយចំនួនផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដែលសិក្ខាកាមនៅមានភាពស្រពិចស្រពិលនៅឡើយ ខ)ក្រោយបញ្ចប់វគ្គសិក្ខាកាមទាំងអស់នឹងយល់កាន់តែច្បាស់អំពីសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងរយៈពេលពីរថ្ងៃនៃវគ្គរំលឹកឡើងវិញនេះទទួលបានលទ្ធផលជាផ្លែផ្កា ដូចខាងក្រោម៖

- o សិក្ខាកាមដែលចូលរួមក្នុងវគ្គទាំងអស់ទទួលបាននូវចំណេះដឹងផ្នែកសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចក្នុងការអនុវត្តគម្រោងនៅថ្នាក់ក្រោមជាតិ ដោយបញ្ចៀសបាននូវផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន ដីធ្លី និងសុវត្ថិភាពជនជាតិដើមភាគតិច។

o សិក្ខាកាមមានការយល់ដឹងពីសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចសម្រាប់អនុវត្ត គម្រោងបានប្រសើរជាងមុន ដែលជាគ្រឹះសម្រាប់អនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

o តាមរយៈការវាយតម្លៃបញ្ជីសំណួរមុន និងក្រោយបញ្ចប់វគ្គ បានបង្ហាញថា នៅមុនដំណើរការវគ្គ សិក្ខាកាមដែលមានកម្រិតខ្សោយ៣៣% កម្រិតមធ្យមមាន៤៦% កម្រិតល្អមាន១៩% និងកម្រិតល្អណាស់មាន២%។ ក្រោយដំណើរការវគ្គ សិក្ខាកាមដែលមានកម្រិតខ្សោយបានថយមកនៅត្រឹម ៩% កម្រិតមធ្យមថយមកនៅត្រឹម៣៧% កម្រិតល្អកើនឡើងដល់៥០% និង កម្រិតល្អណាស់មាន ៤%។

• ចូលរួមសម្របសម្រួលក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីបរិស្ថាន និងសង្គមរយៈពេល២ថ្ងៃក្នុងគម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ(LEAP)នៅខេត្តសៀមរាប ដែលរៀបចំដោយក្រសួងមហាផ្ទៃជាមួយធនាគារពិភពលោក(The World Bank)។ សិក្ខាសាលានេះ បានបណ្តុះបណ្តាលដល់មន្ត្រីគាំទ្រគម្រោងក្នុង៤៧ឃុំ សង្កាត់ ក្នុង៩ក្រុង ស្រុក នៃខេត្តសៀមរាប។ សិក្ខាសាលាបណ្តុះបណ្តាលនេះ ផ្តោតលើគោលដៅ តាមរយៈ ក)បង្កើត និងពង្រឹងស្ថាប័នស្វ័យគ្រប់គ្រងរបស់អ្នកក្រ ខ)ផ្តល់ឱ្យស្ថាប័នទាំងនោះ នូវលទ្ធភាពចាប់យកហិរញ្ញវត្ថុ និង គ)ផ្សារភ្ជាប់ស្ថាប័នទាំងនោះទៅនឹងទីផ្សារ និងមុខរបរសំខាន់ៗ និងបានចូលរួមផ្តល់យោបល់និងបង្ហាញការអនុវត្តផ្ទាល់អំពីការសិក្សាសុវត្ថិភាពបរិស្ថាននិងសង្គមដល់សិក្ខាកាមដែលបានចូលរួមទាំងអស់នៅទីតាំងអនុវត្តគម្រោងចំនួនពីរកន្លែងនៅក្នុងសង្កាត់ស្វាយដង្គំ ក្នុងក្រុងសៀមរាប ។

## ២.៦. ការគាំទ្រ និងកិច្ចសហការ

ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានសម្របសម្រួលជាមួយទីចាត់ការផែនការ និងវិនិយោគខេត្តទាំងអស់ដើម្បីពន្លឿនការសិក្សាកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច និងដើម្បីផ្ញើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងរបាយការណ៍វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមកទីប្រឹក្សានិងមន្ត្រីផ្នែកនេះ ដើម្បីពិនិត្យនិងផ្តល់យោបល់បច្ចេកទេសគម្រោងបានទាន់ពេលវេលា ដេញថ្លៃ និងបានឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ។

## ៣. បញ្ហា

### ផ្នែកសុវត្ថិភាពបរិស្ថាន

ផ្នែកសុវត្ថិភាពបរិស្ថាន ក្រុមមន្ត្រីអនុវត្តគម្រោងមួយចំនួនតូចនៅថ្នាក់ក្រោមជាតិ បានបំពេញឯកសាររបាយការណ៍វិភាគបរិស្ថានរបស់គម្រោងមានការខ្វះចន្លោះ មានដូចខាងក្រោម៖

o ការបំពេញទម្រង់របាយការណ៍វិភាគបរិស្ថានរបស់គម្រោង មន្ត្រីដែលមានតួនាទីអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថានមិនសូវបានយកចិត្តទុកដាក់បំពេញឱ្យបានត្រឹមត្រូវ នាំឱ្យមានការយឺតយូរពន្យាពេលដេញថ្លៃគម្រោង

### ផ្នែកសុវត្ថិភាពដីធ្លី

ផ្នែកសុវត្ថិភាពដីធ្លីនេះ ក្រុមមន្ត្រីអនុវត្តគម្រោងនៅថ្នាក់ក្រោមជាតិ បានជួបប្រទះនូវបញ្ហាដែលជាការលំបាកសម្រាប់ពួកគាត់ដែលជាអ្នកអនុវត្តគម្រោង មានដូចខាងក្រោម៖

o មន្ត្រីដែលមានតួនាទីអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីរបស់គម្រោងនៅថ្នាក់ក្រោមជាតិក្នុងខេត្តមួយចំនួនមានការលំបាកអញ្ជើញប្រជាពលរដ្ឋចូលរួមប្រជុំពិភាក្សានៅតាមក្បាលដីនីមួយៗដោយសារ

ម្ចាស់ក្បាលដីខ្លះបានចេញទៅប្រកបការងារនៅក្រៅស្រុក និងនៅក្រៅប្រទេស នាំឱ្យមានការពន្យាពេលដេញថ្លៃគម្រោង ជាហេតុនាំឱ្យមានការអនុវត្តខុសពីនីតិវិធីក្នុងសៀវភៅ ភីម ខ្លះៗ។

- ការយកចិត្តទុកដាក់របស់មន្ត្រីអនុវត្តគម្រោងបានបំពេញ និងរៀបចំឯកសារគម្រោងផ្ទុយនិងនីតិវិធីអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីក្នុងសៀវភៅ ភីម នាំឱ្យមានការផ្ញើឯកសារចុះឡើងដើម្បីរៀបចំឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ។
- មន្ត្រីអនុវត្តគម្រោងបានសរសេរកំណត់ហេតុពិភាក្សា និងព្រមព្រៀង មុនការផ្តិតមេដៃបរិច្ចាគដីធ្លីនិងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តឱ្យគម្រោងនៅក្នុងទម្រង់ទី២១.៥ ដែលផ្ទុយនឹងគោលការណ៍ណែនាំ
- មន្ត្រីអនុវត្តគម្រោងបានអនុវត្តន៍ការវាស់វែងដំណាលគ្នាជាមួយនិងការពិភាក្សានិងព្រមព្រៀងក្នុងថ្ងៃតែមួយដែលផ្ទុយនិងនីតិវិធីអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីក្នុងសៀវភៅភីម។

## ៤. ការសន្និដ្ឋាន

ក្នុងឆ្នាំ២០១៩នេះ ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានអនុវត្តស្របទៅតាមផែនការសកម្មភាព និងថវិកាដែលបានគ្រោងទុក។ សកម្មភាពទាំងនោះ មានដូចជា រៀបចំចងក្រងបញ្ជីគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោង ខេត្តដែលថ្នាក់ក្រោមជាតិបានផ្ញើមកដើម្បីបានផ្ទៀងផ្ទាត់ក្នុងការពិនិត្យនិងផ្តល់យោបល់បច្ចេកទេសត្រលប់ទៅថ្នាក់ក្រោមជាតិវិញឱ្យបានមុនពេលដេញថ្លៃគម្រោង។ ជាមួយគ្នានេះដែរ ក្រុមសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានធ្វើការពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើរបាយការណ៍អនុវត្តសុវត្ថិភាពបរិស្ថាន និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោងឆ្នាំ២០១៨ដែលនៅសេសសល់ រួមជាមួយគម្រោងឆ្នាំ២០១៩ឱ្យបានមុនដេញថ្លៃ។ ក្រុមសុវត្ថិភាពបានចូលរួមរៀបចំ គោលនយោបាយបរិស្ថាន និងសង្គម និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យលើបរិស្ថាន និងសង្គមសម្រាប់ការអនុវត្តគម្រោងក្នុងក្របខណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងបានផ្សព្វផ្សាយគោលនយោបាយ និងគោលការណ៍ណែនាំនេះនៅថ្នាក់ជាតិចំនួនមួយលើក ។

នៅអំឡុងដើមឆ្នាំ ក្រុមសុវត្ថិភាពបានចូលរួមជាមួយមន្ត្រី និងទីប្រឹក្សាគម្រោងជាប់ដោយឡែក របស់លេខាធិការដ្ឋាន គ.ជ.អ.ប ដោយបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិចដល់មន្ត្រីអនុវត្តក្នុងគម្រោង TSDD គម្រោង LGCC II គម្រោង SRL ឱ្យបានមុនពេលអនុវត្តគម្រោង។ ទាក់ទងទៅនឹងការងារចុះតាមដានការអនុវត្តសុវត្ថិភាពដីធ្លីរបស់គម្រោង ក្រុមសុវត្ថិភាពបានចុះត្រួតពិនិត្យឯកសាររបាយការណ៍និងការអនុវត្តសុវត្ថិភាពដីធ្លីរបស់គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៨ និងបានចុះពិនិត្យដល់ទីតាំងគម្រោងនៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង ដើម្បីប្រាកដថា នៅថ្នាក់ក្រោមជាតិបានអនុវត្តន៍តាមការណែនាំនៅក្នុងសៀវភៅភីមឬក៏មិនបានអនុវត្ត។ ការចុះត្រួតពិនិត្យក្នុងខេត្តទាំងពីរនេះ ក្រុមការងារសុវត្ថិភាពបានរកឃើញភាពខ្វះចន្លោះមួយចំនួនក្នុងការបំពេញទម្រង់ឯកសាររបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្តឱ្យគម្រោង នៅក្នុងទម្រង់ឯកសារទាំងនោះ មានដូចជា៖

ក)ចុះកាលបរិច្ឆេទលើទម្រង់លទ្ធកម្មដីធ្លីដំណាលគ្នានឹងថ្ងៃព្រមព្រៀងបរិច្ចាគដែលមិនសមស្របនឹងនីតិវិធីក្នុងសៀវភៅភីម និងចន្លោះដែលមិនមានទិន្នន័យមិនដាក់លេខសូន្យ។

ខ)មានការសរសេរកំណត់ហេតុព្រមព្រៀងបរិច្ចាគដីធ្លី និងដើមឈើដំណាំហូបផ្លែមុនការផ្តិតមេដៃបរិច្ចាគក្នុង(ទម្រង់ទី២១.៥)។

ឃ)ក្នុងបញ្ជីឈ្មោះអ្នកចូលរួមអង្កេតដីធ្លីបានចុះអង្កេតវាស់វែងដំណាលគ្នានឹងព្រមព្រៀង និងមានប្រើទម្រង់របស់សៀវភៅភីមចាស់ ។

ង)របាយការណ៍បរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តមិនមានភ្ជាប់កំណត់ហេតុប្រជុំពិភាក្សា និងព្រមព្រៀង។

ច)ការជូនដំណឹងស្តីពីការពិនិត្យបញ្ជាក់បច្ចេកទេស(ទម្រង់ទី៤)មិនបានសរសេរកាលបរិច្ឆេទដែលបានទទួលឯកសារពិនិត្យ និងផ្តល់យោបល់ពីលេខាធិការដ្ឋាន គ.ជ.អ.ប សម្រាប់បញ្ចូលក្នុងប្រព័ន្ធទិន្នន័យគម្រោង (PID)។

ឆ)មានការចុះកាលបរិច្ឆេទក្នុងទម្រង់លទ្ធកម្មដីធ្លី ក្នុងគម្រោងភាគច្រើនមានរយៈពេលឃ្លាតឆ្ងាយពីគ្នាពីទម្រង់បញ្ជីឈ្មោះអ្នកចូលរួមអង្កេតដីធ្លីដែលជាឯកសារស្រង់ទិន្នន័យផលប៉ះពាល់ដំបូងគេបង្អស់។

ជ)ក្នុងទម្រង់របាយការណ៍បរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តឱ្យគម្រោង(ទម្រង់ទី២១.១០) មន្ត្រីអនុវត្តគម្រោងនៅឃុំសង្កាត់មួយចំនួន មិនបានចុះកាលបរិច្ឆេទចាប់ផ្តើមអនុវត្តគម្រោង។

ឈ)មន្ត្រីអនុវត្តគម្រោងនៅឃុំ សង្កាត់ ភាគច្រើនបានចុះស្រង់ទិន្នន័យដំណាលគ្នានឹងព្រមព្រៀងបរិច្ចាគដែលខុសពីនីតិវិធីក្នុង សៀវភៅ (ភីម) តម្រូវឱ្យធ្វើការអង្កេត និងប្រមូលទិន្នន័យយ៉ាងហោចណាស់រយៈពេលពីរសប្តាហ៍មុនព្រមព្រៀង។

៣)ស្មៀនឃុំបានចុះកាលបរិច្ឆេទដោយកុំព្យូទ័រទុកជាមុននៅក្នុងទម្រង់ឯកសារបញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តឱ្យគម្រោង (ទម្រង់ទី២១.៥)ដែលជាឯកសារគតិយុត្ត ។

## ៥. អនុសាសន៍

ដើម្បីពង្រឹងការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក ខណ្ឌ ឱ្យបានឆ្លើយតបទៅនឹងតាមគោលការណ៍ណែនាំ ដែលមានចែងក្នុងសៀវភៅភីម និងលិខិតណែនាំនានា លុះត្រាតែ៖

- o បង្កើនការចុះតាមដាន ត្រួតពិនិត្យ និងចុះដល់ទីតាំងគម្រោងឱ្យបានញឹកញាប់ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបានបំពេញ រៀបចំទុកដាក់ឯកសារគម្រោង និងការអនុវត្តកិច្ចការពារសុវត្ថិភាពជាក់ស្តែងនៅទីតាំងគម្រោង ស្វែងរកចំណុចខ្វះចន្លោះមកប្រជុំឆ្លុះបញ្ចាំង និងផ្តល់មតិណែនាំដល់មន្ត្រីអនុវត្តន៍គម្រោងលើការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចឱ្យបានល្អជាប្រចាំ។
- o មន្ត្រីទីចាត់ការផែនការ និងវិនិយោគខេត្តដែលទទួលបន្ទុកអនុវត្តការងារកិច្ចការពារសុវត្ថិភាពរបស់គម្រោងត្រូវពង្រឹងការសិក្សាសុវត្ថិភាពរបស់គម្រោង ដោយត្រូវសហការអនុវត្តកិច្ចការពារសុវត្ថិភាពនេះឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា ព្រមទាំងបង្កើននូវការតាមដានត្រួត ពិនិត្យពេលអនុវត្តន៍គម្រោង និងថែទាំលទ្ធផលគម្រោងឱ្យបានជាប់ជាប្រចាំ ។
- o មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ខេត្ត ត្រូវបង្កើនកិច្ចសហការគ្នាចុះសិក្សា តាមដាន និងត្រួតពិនិត្យជាមួយគ្នាលើការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងក្នុងពេលតែមួយជាមួយគ្នា និងត្រូវផ្តល់ព័ត៌មានដល់គ្នាទៅវិញទៅមកជាប្រចាំ ។

o មន្ត្រីគាំទ្រការអនុវត្តគម្រោងនៃទីចាត់ការផែនការ និងវិនិយោគខេត្ត ដែលទទួលខុសត្រូវនៅក្នុងឃុំសង្កាត់របស់ខ្លួន ត្រូវខិតខំពង្រឹងការងារសិក្សាសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចគម្រោងឱ្យកាន់ស្ទាត់ជំនាញបន្ថែមទៀតសម្រាប់ចុះជួយគាំទ្រគម្រោងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ។

o យោងតាមគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលទើបតែអនុម័តឱ្យប្រើប្រាស់ថ្មីៗនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ គួរពិនិត្យលទ្ធភាពបញ្ជូនមន្ត្រីដែលពាក់ព័ន្ធនឹងការជួយគាំទ្រគម្រោងនៅថ្នាក់ក្រោមជាតិបានចូលរួមក្នុងវគ្គផ្សព្វផ្សាយគោលនយោបាយ និងគោលការណ៍ណែនាំថ្មីនេះ ឱ្យបានចំនួនច្រើនជាងមុន ដើម្បីបង្ការជំនួសកន្លែងអ្នកដែលមានស្នាដៃការងារល្អអាចផ្លាស់ទៅបម្រើការងារនៅកន្លែងថ្មី។

## ៦. សកម្មភាពសំខាន់ៗសម្រាប់ ឆ្នាំ២០២០

សម្រាប់ឆ្នាំ២០២០ ផែនការសកម្មភាពផ្នែកសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានចំណុចសំខាន់ៗមួយចំនួនដែលត្រូវអនុវត្តន៍ ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ សម្រាប់ការងារសុវត្ថិភាពបរិស្ថាន និងសង្គម។
- ធ្វើការទំនាក់ទំនងជាមួយក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍជនបទ ក្រសួងវប្បធម៌ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីរៀបចំឡើងវិញកំណត់នូវតំបន់ដែលមានឃុំ សង្កាត់ក្នុងតំបន់ការពារ និងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឱ្យបានសមស្របតាមស្ថានភាពបច្ចុប្បន្ន ។
- ផ្សព្វផ្សាយគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យលើបរិស្ថាននិងសង្គមសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យលើបរិស្ថាននិងសង្គមក្នុងក្របខណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដល់មន្ត្រីពាក់ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- កែសម្រួលទម្រង់មួយចំនួនផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងឱ្យបានសមស្របតាមគោលនយោបាយស្តីពីបរិស្ថាននិងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីប្រើប្រាស់អនុវត្តគម្រោង។
- ធ្វើការទំនាក់ទំនងជាមួយក្រុមព័ត៌មានវិទ្យា(IT)របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីបានធ្វើបច្ចុប្បន្នភាពបន្ថែមលើការត្រួតពិនិត្យគម្រោង។
- ចូលរួមតាមការអញ្ជើញរបស់ថ្នាក់ក្រោមជាតិដើម្បីជួយសម្របសម្រួលក្នុងវគ្គរំលឹកឡើងវិញស្តីពីគោលការណ៍ណែនាំការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង។
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសាររបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត។
- ចុះតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីរបស់គម្រោងរបស់ថ្នាក់ក្រោមជាតិ និងចុះត្រួតពិនិត្យជាក់ស្តែងនៅទីតាំងគម្រោង។
- ចុះតាមដានការអនុវត្តសុវត្ថិភាពបរិស្ថាន និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោងរបស់ថ្នាក់ក្រោមជាតិ ក្នុងករណីរកឃើញថាមិនបានអនុវត្តត្រឹមត្រូវតាមគោលការណ៍ណែនាំ។

- ចូលរួមសម្របសម្រួលជាមួយអង្គភាពនានាចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលវគ្គរំលឹកឡើងវិញ និងសិក្ខាសាលានានាដល់មន្ត្រីពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ។
- រៀបចំរបាយកាយណ៍រីកចម្រើនប្រចាំខែ និងប្រចាំឆ្នាំដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប.។

**រៀបចំដោយ**
**ក្រុមសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច**
**នៃលេខាធិការដ្ឋាន គ.ជ.អ.ប.**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
**លេខាធិការដ្ឋាន** (គ.ជ.អ.ប)

**អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី**
លេខៈ.........០៣...................../ អ.គ.គ.ក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃ..ចន្ទ..១២កើត.... ខែ..បុស្ស.... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី..០៦..............ខែ..មករា.......ឆ្នាំ២០២០..

## សូមគោរពជូន

## ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

**កម្មវត្ថុ** ៖ របាយការណ៍សង្ខេបស្តីពីលទ្ធផលការងារសុវត្ថិភាពបរិស្ថាន និងសង្គមប្រចាំឆ្នាំ២០១៩ ។

**យោង** ៖ ផែនការសកម្មភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ឆ្នាំ២០១៩។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា កិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម នៅតែជាយន្តការមួយដែលមានភាពចាំបាច់ក្នុងកិច្ចដំណើរការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីបានបន្តជំរុញការអនុវត្តយន្តការមួយនេះ ដែលតម្រូវឱ្យអ្នកអនុវត្តគម្រោងត្រូវតែមានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ជាមុនចំពោះហានិភ័យលើបរិស្ថាន និងសង្គម អាចនឹងកើតមានឡើងដោយសារការអនុវត្តម្រោង។

ក្នុងឆ្នាំ២០១៩នេះ មន្ត្រី និងទីប្រឹក្សាសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប បានខិតខំបំពេញការងាររបស់ខ្លួនតាមផែនការសកម្មភាព និងថវិកាដែលបានកំណត់ដោយបានយកចិត្តទុកដាក់ និងមានការទទួលខុសត្រូវ រហូតទទួលបានលទ្ធផល ដូចខាងក្រោម៖

១. បានសម្របសម្រួលជាមួយនាយក នាយករង និងមន្ត្រីនៃទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីហេដ្ឋារចនាសម្ព័ន្ធខេត្ត បានរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក គម្រោងខេត្តឆ្នាំ២០១៩ របស់ខេត្តទាំង២៤ និងបានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងនេះរៀងរាល់ខែតាមសកម្មភាពរបស់ថ្នាក់ក្រោមជាតិដែលបានស្នើឡើង។ បញ្ជីគម្រោងទាំងនោះមានដូចខាងក្រោម៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសរុបមានចំនួន១៦៣៩គម្រោងនៃ១៥៣៧ឃុំ សង្កាត់ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបមានចំនួន៦៧៨គម្រោង តម្រូវការសិក្សាដីធ្លីសរុបមានចំនួន២៣៦គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបមានចំនួន៨៤គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមានចំនួន៦៧៦គម្រោង និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចសរុបមានចំនួន៨៤គម្រោង។

សូមបញ្ជាក់ជូនថា ប្រៀបធៀបពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៩ ចំនួនគម្រោងមូលនិធិឃុំ សង្កាត់ដែលតម្រូវការសិក្សាសុវត្ថិភាពដីធ្លីមានការថយចុះចំនួន៣៨៨គម្រោង គឺតួលេខក្នុងឆ្នាំ២០១៥មានចំនួន

៦២២គម្រោង និងតួលេខក្នុងឆ្នាំ២០១៩ មានចំនួន២៣៦គម្រោង។ ចំនួនគម្រោងសិក្សាដីធ្លីថយចុះនេះ ដោយសារនៅឃុំសង្កាត់បានអនុវត្តសាងសង់ផ្លូវបេតុងអាមេរ៍ច្រើនជាងផ្លូវដីស និងផ្លូវក្រួសក្រហម។

ខ). គម្រោងមូលនិធិក្រុង ស្រុក មានខេត្តចំនួន១៣ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៩ មានចំនួនសរុប២០៧គម្រោងនៃ៨៧ក្រុង ស្រុក ខណ្ឌ។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន ៨៦គម្រោង តម្រូវការសិក្សាដីធ្លីមានចំនួន១២គម្រោង តម្រូវការសិក្សាជនជាតិដើមភាគតិចមាន១១គម្រោង។ គម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបចំនួន ៨៦គម្រោង និងនៅក្នុងតំបន់ជនជាតិដើមភាគតិចសរុបចំនួន១១គម្រោង។

គ). គម្រោងមូលនិធិរាជធានី ខេត្ត មានខេត្តចំនួន៧បានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៩ មានចំនួនសរុប៥៥គម្រោង ។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន១៥គម្រោង តម្រូវការសិក្សាដីធ្លីមានចំនួន៩គម្រោង តម្រូវការសិក្សាជនជាតិដើមភាគតិចមាន១៩គម្រោង។ គម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបចំនួន១៥គម្រោង និងនៅក្នុងតំបន់ជនជាតិដើមភាគតិចសរុបចំនួន១៩គម្រោង។

២. បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន និងតំបន់ជនជាតិដើមភាគតិចមុនដេញថ្លៃគម្រោង មានដូចខាងក្រោម៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានចំនួនសរុប៥១៧គម្រោង ស្មើនឹង៧៦%នៃចំនួនសរុប៦៧៦គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន៥៦គម្រោង ស្មើនឹង៨0% នៃចំនួន៨៣គម្រោង ដែលស្ថិតក្នុងបញ្ជីជនជាតិដើមភាគតិច។ ក្នុងនេះ មានគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅមូលដ្ឋានដែលហៅកាត់ថា ASPIRE គម្រោងSRL ភ្ជាប់ជាមួយគម្រោងឃុំ សង្កាត់ផងដែរ។

ខ).បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិក្រុង ស្រុក ខណ្ឌ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានដែលស្ថិតនៅក្នុងបញ្ជីងាយរងទទួលផលប៉ះពាល់បរិស្ថានសរុបចំនួន ៨៦គម្រោងស្មើនឹង៧១%នៃ១២១គម្រោងនិងរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន៨គម្រោងស្មើនិង៧៣%នៃ១១គម្រោង។

គ).បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថានសរុបចំនួន២៤គម្រោងស្មើនឹង៦៧%នៃគម្រោងសរុបចំនួន៣៦គម្រោង និងមិនមានគម្រោងតម្រូវការសិក្សាលើវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចទេ។

៣. បានចុះត្រួតពិនិត្យឯកសាររបាយការណ៍ និងការអនុវត្តសុវត្ថិភាពដីធ្លីរបស់គម្រោងនៅទីចាត់ការផែនការនិងវិនិយោគខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ ក្រុមការងារបានពិនិត្យគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៨ ក្នុងនោះគម្រោងស្នើឡើងសរុបចំនួន១៤៨គម្រោង គម្រោងតម្រូវការ

សិក្សាដីធ្លីមានចំនួន៤២គម្រោង។ ក្នុងគម្រោងសរុបចំនួន១៤៨នេះ បានចុះកិច្ចសន្យានិងអនុវត្តន៍បាន១០០% ទាំងអស់។ គម្រោងដែលបានត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីសរុបចំនួន៣២គម្រោងស្មើនឹង៨៤%នៃគម្រោងសិក្សាដីធ្លីទាំងអស់។ សង្កេតឃើញថា ការបំពេញឯកសាររបាយការណ៍ និងការអនុវត្តសុវត្ថិភាពដីធ្លីគម្រោងឃុំសង្កាត់ឆ្នាំ២០១៨របស់ខេត្តទាំងពីបានល្អបង្គួរ តែនៅមានភាពខ្វះចន្លោះមួយចំនួនក្នុងការបំពេញឯកសារទម្រង់របាយការណ៍ និងការគូរផែនទីអង្កេតដីធ្លីមិនទាន់បានត្រឹមត្រូវ។

៤. ការពង្រឹងសមត្ថភាពនៅថ្នាក់ជាតិះ

- បានចូលរួមប្រជុំពិភាក្សាស្តីពីការរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីបរិស្ថាននិងសង្គម និងគោលនយោបាយស្តីពីសមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលបានរៀបចំនៅសាលប្រជុំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។
